

# PRU MyHealth

## សុវត្ថិភាពផ្លូវចិត្តចំពោះការចំណាយទៅលើវេជ្ជសាស្រ្ត

PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# សុខភាពគឺជាទ្រព្យ

សុខភាពគឺជាកំណប់ទ្រព្យដែលមិនអាចកាត់ថ្លៃបាន និងជាមូលដ្ឋានគ្រឹះដ៏ធំបំផុតសម្រាប់មនុស្សម្នាក់ដើម្បីសម្រេចបាននូវគោលបំណងក្នុងជីវិត។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាទាក់ទងនឹងសុខភាពក៏អាចកើតឡើងដោយមិនដឹងខ្លួន និងអាចប៉ះពាល់យ៉ាងខ្លាំងដល់ដំណើរជីវិត។

ដោយការមើលឃើញអំពីបញ្ហា  ក្រុមហ៊ុនព្រូដិនសលសូមណែនាំកញ្ចប់ផលិតផល **PRUសុខភាពខ្ញុំ** ដែលជួយប្រជាជនកម្ពុជារាប់លាននាក់សម្រេចបាននូវគោលដៅជីវិតឱ្យរស់នៅប្រកបដោយសុភមង្គល និងរីករាយគ្រប់ពេលជាមួយមនុស្សជាទីស្រលាញ់។



# គម្រោងថែទាំសុខភាពសម្រាប់ផលិតផល
# PRUសុខភាពខ្ញុំ

| | អត្ថប្រយោជន៍ (ជាដុល្លារអាមេរិក ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង) | កញ្ចប់សំរឹទ្ធ | កញ្ចប់ប្រាក់ | កញ្ចប់មាស | កញ្ចប់ពេជ្រ |
|---|---|---|---|---|---|
| | ទីតាំងភូមិសាស្ត្រ | ប្រទេសកម្ពុជា | ប្រទេសកម្ពុជា វៀតណាម និងថៃ | ប្រទេសក្នុងតំបន់អាស៊ានលើកលែងសិង្ហបុរី | ប្រទេសក្នុងតំបន់អាស៊ាន |
| | ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប[1] (អនុវត្តទៅលើចំណុចទី ១ ដល់ទី ៤) | $5,000 | $10,000 | $30,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា $10,000) | $50,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា $10,000) |
| | ចំនួនអតិបរិមាក្នុងការចូលរួមចំណែកក្នុងការចំណាយ (២០%) ក្នុង ១ ហេតុការណ៍[2] | $100 | $150 | $500 | $700 |
| **1** | **ការព្យាបាលជំងឺមហារីក** | | | | |
| 1.1 | ការសម្រាកព្យាបាលជំងឺមហារីកដោយសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងមិនសម្រាកនៅមន្ទីរពេទ្យ(រួមមានការព្យាបាលដោយប្រើគីមី ការព្យាបាលដោយកាំរស្មី ការព្យាបាលដោយកំណត់គោលដៅ) (មិនមានទំហំអត្ថប្រយោជន៍តាមប្រភេទប៉ុន្តែទំហំអត្ថប្រយោជន៍ថ្លៃបន្ទប់ និងការស្នាក់នៅអនុវត្តតាមចំណុច ១.២) | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប |
| 1.2 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម ៨0 ថ្ងៃរួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម ICU) | $25 | $50 | $250 | $500 |
| **2** | **ការសម្រាកព្យាបាល ដែលមិនមែនជាការព្យាបាលជំងឺមហារីក ទំហំអត្ថប្រយោជន៍រង (លើកលែងជំងឺមហារីក)** | | | | |
| 2.1 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម ៨0 ថ្ងៃរួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម ICU) | $25 | $50 | $250 | $500 |
| 2.2 | ថ្លៃចំណាយជាក់ស្តែងផ្នែកប្រពោធនកម្មក្នុងមួយថ្ងៃ (ច្រើនបំផុតត្រឹម៣០ថ្ងៃ) | $50 | $100 | $500 | $1,000 |
| 2.3 | ថ្លៃចំណាយជាក់ស្តែងទៅលើការវះកាត់ដោយសម្រាកនៅមន្ទីរពេទ្យ | $500 | $1,000 | $10,000 | $25,000 (សម្រាប់ប្រទេសកម្ពុជា $10,000) |
| 2.4 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលមុនពេលចូលសម្រាកនៅមន្ទីរពេទ្យ (រហូតដល់៣០ថ្ងៃមុនថ្ងៃចូលសម្រាកមន្ទីរពេទ្យ) | $100 | $250 | $500 | $1,000 |
| 2.5 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលក្រោយពេលចាកចេញពីមន្ទីរពេទ្យច្រើនបំផុតត្រឹម ៥ ដង (៦០ ថ្ងៃបន្ទាប់ពីចេញពីមន្ទីរពេទ្យ) | $100 | $250 | $500 | $1,000 |
| 2.6 | ថ្លៃចំណាយជាក់ស្តែងទៅលើសេវាក្នុងមន្ទីរពេទ្យ និងសេវាពាក់ព័ន្ធផ្សេងៗ | $1,000 | $2,000 | $6,000 | $10,000 |
| 2.7 | ថ្លៃចំណាយជាក់ស្តែងទៅលើរថយន្តសង្គ្រោះបន្ទាន់ | $50 | $100 | $300 | $500 |

# គម្រោងថែទាំសុខភាពសម្រាប់ផលិតផល
# PRUសុខភាពខ្ញុំ

| អត្ថប្រយោជន៍ (ជាដុល្លារអាមេរិក ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង) | | កញ្ចប់សំរឹទ្ធ | កញ្ចប់ប្រាក់ | កញ្ចប់មាស | កញ្ចប់ពេជ្រ |
|---|---|---|---|---|---|
| ទីតាំងភូមិសាស្រ្ត | | ប្រទេសកម្ពុជា | ប្រទេសកម្ពុជា វៀតណាម នឹងថៃ | ប្រទេសក្នុងតំបន់អាស៊ានលើកលែងសិង្ហបុរី | ប្រទេសក្នុងតំបន់អាស៊ាន |
| ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប[1] (អនុវត្តទៅលើចំណុចទី ១ ដល់ទី ៤) | | $5,000 | $10,000 | $30,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា $10,000) | $50,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា $10,000) |
| ចំនួនអតិបរិមាក្នុងការចូលរួមចំណែកក្នុងការចំណាយ (២០%) ក្នុង ១ ហេតុការណ៍[2] | | $100 | $150 | $500 | $700 |
| **3** | **ការព្យាបាលដោយមិនចាំបាច់សម្រាកនៅមន្ទីរពេទ្យ** | | | | |
| 3.1 | ថ្លៃចំណាយជាក់ស្តែងទៅលើការវះកាត់ក្នុងថ្ងៃ | $100 | $200 | $500 | $2,000 |
| 3.2 | ថ្លៃចំណាយជាក់ស្តែងទៅលើការលាងឈាម | $500 | $1,000 | $3,000 | $5,000 |
| **4** | **ផលវិបាកនៃការមានគភ៌ (អ្នកត្រូវបានធានារ៉ាប់រងត្រូវតែមានអាយុចាប់ពី ២០-៤៩ ឆ្នាំ)** | | | | |
| 4.1 | ថ្លៃសម្រាកព្យាបាលនៅឬមិននៅមន្ទីរពេទ្យជាក់ស្តែង (រយៈពេលរង់ចាំ ៣៦៥ថ្ងៃ) | $500 | $1,000 | $3,000 | $5,000 |
| **5** | **PRUអ្នកការពារ[4] (ករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ (ដោយសារគ្រោះថ្នាក់ចៃដន្យ ឬ មិនមែនគ្រោះថ្នាក់ចៃដន្យ)** | | | | |
| 5.1 | ករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍[3] (ដោយមូលហេតុណាមួយ) | $5,000 | $10,000 | $30,000 | $50,000 |

**ចំណាំ**

**(១) ៖** ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប គឺជាចំនួនទឹកប្រាក់អតិបរមាទូទាត់សម្រាប់ការចំណាយវេជ្ជសាស្រ្តដែលកើតឡើងសម្រាប់សេវាចាំបាច់ផ្នែកវេជ្ជសាស្រ្តក្នុងអំឡុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។ ទំហំអត្ថប្រយោជន៍រង គឺជាការចំណាយជាអតិបរមាទៅលើប្រភេទនៃការចំណាយវេជ្ជសាស្រ្តនីមួយៗដែលកើតឡើងសម្រាប់សេវាចាំបាច់ផ្នែកវេជ្ជសាស្រ្តក្នុងអំឡុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។

**(២) ៖** ការចូលរួមចំណែកក្នុងការចំណាយ គឺជាចំនួនទឹកប្រាក់នៃថ្លៃព្យាបាលជាក់ស្តែងដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវទទួលខុសត្រូវក្នុងការបង់សម្រាប់ព្រឹត្តិការណ៍ធានារ៉ាប់រងនីមួយៗ។ទំនួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងការចូលរួមចំណែកក្នុងការចំណាយ អាច លើសពីចំនួនទឹកប្រាក់កំណត់ នៅពេលដែលការទាមទារសំណងសម្រាប់ប្រភេទនៃការចំណាយវេជ្ជសាស្រ្តនីមួយៗ លើសពីទំហំអត្ថប្រយោជន៍រង។

**(៣) ៖** ក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេល ឬ បន្ទាប់ពីពេលចាកចេញពី មន្ទីរពេទ្យ អត្ថប្រយោជន៍នៃការចំណាយវេជ្ជសាស្រ្តសម្រាប់ការព្យាបាលចុងក្រោយ នៅមុនពេលមានការបញ្ជាក់ពីមរណភាព ឬ ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ដោយវេជ្ជបណ្ឌិត នឹងអាចទាមទារសំណងបាន។ បណ្ណសន្យារ៉ាប់រងនឹងត្រូវ បញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍មរណភាព ឬ ពិការទាំងស្រុង និងជាអចិន្ត្រៃយ៍។

**(៤) ៖** កញ្ចប់PRUសុខភាពខ្ញុំ គឺរួមបញ្ចូលជាមួយ ធានារ៉ាប់រងបន្ថែមPRUសុខភាពខ្ញុំភ្ជាប់មកជាមួយកញ្ចប់មូលដ្ឋានPRUអ្នកការពារ។

ហេតុអ្វីបានជាត្រូវជ្រើសរើស

# PRUសុខភាពខ្ញុំ

- ផ្តោតលើអត្ថប្រយោជន៍សុខភាពរបស់លោកអ្នក ដែលចំណាយថ្លៃព្យាបាលរបស់អ្នករហូតដល់ ជាសះស្បើយ។
- អត្ថប្រយោជន៍ 100%ទៅលើករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដោយសារមូលហេតុណាមួយ។
- អត្ថប្រយោជន៍លើការចំណាយព្យាបាលរហូតដល់ 100% ចាប់ផ្តើមពីឆ្នាំទី 1។
- ការធានារ៉ាប់រងមុនចូលមន្ទីរពេទ្យរហូតដល់ 30 ថ្ងៃនិងអត្ថប្រយោជន៍ក្រោយពេលសម្រាកនៅមន្ទីរពេទ្យរហូតដល់ 60 ថ្ងៃ។
- មិនចាំបាច់ទូទាត់ប្រាក់ផ្ទាល់ខ្លួន បើសិនព្យាបាលជាមួយមន្ទីរពេទ្យ ឬស្ថាប័នដែលជាដៃគូសហការរបស់ព្រូដិនសល។



# PRU MyHealth

**ការបង្ហាញទី១៖** លោក ជា សម្បត្តិ អាយុ៣៥ឆ្នាំ ទិញ **PRUសុខភាពខ្ញុំ** កញ្ចប់សិរីទ្ធ ដែលមានអត្ថប្រយោជន៍ចំនួន ៥,០០០ដុល្លារអាមេរិក។ គាត់ត្រូវបានចូលសម្រាកក្នុងមន្ទីរពេទ្យអស់រយៈពេល៣០ថ្ងៃ ដោយសារជំងឺ ដែលជំងឺនោះស្ថិតនៅក្រោមការការពារ (ថ្លៃចំណាយជាក់ស្តែងសរុបតាមផ្នែកនីមួយៗសម្រាប់ការទាមទារសំណងលើកទី១ត្រូវបានបង្ហាញដូចខាងក្រោម៖

| អត្ថប្រយោជន៍ | ថ្លៃចំណាយជាក់ស្តែង | អត្ថប្រយោជន៍ទូទាត់សំណងមុនពេលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកក្នុងការចំណាយ (២០%) | ក្រោយដកចេញការចូលរួមចំណែកក្នុងការចំណាយ (២០%) |
|---|---|---|---|---|
| ថ្លៃបន្ទប់ និង ការស្នាក់នៅ | $900<br>($30 ក្នុងមួយថ្ងៃ x30) | $750<br>($25 ក្នុងមួយថ្ងៃ x30) | $150 | $600 |
| ការវះកាត់ដោយសម្រាកនៅមន្ទីរពេទ្យ | $600 | $500 | $100 | $400 |
| សេវាក្នុងមន្ទីរពេទ្យ និងសេវាពាក់ព័ន្ធផ្សេងៗ | $1,000 | $1,000 | $200 | $800 |
| ការកែតម្រូវលើដែនកំណត់នៃការចូលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកអតិបរមាក្នុងហេតុការណ៍តែមួយគឺ ១០០ដុល្លារអាមេរិក។ ទឹកប្រាក់៣៥០ ដុល្លារអាមេរិកត្រូវបានសងត្រលប់ទៅអតិថិជនវិញ។ | | | $350 |
| **អត្ថប្រយោជន៍ត្រូវទូទាត់ជូន** | $2,500 | $2,250 | $100 | **$2,150** |



ចំនួនទឹកប្រាក់សំណង **២,១៥០ដុល្លារអាមេរិក** ត្រូវបានទូទាត់ជូន។ បណ្ណសន្យារ៉ាប់រងនៅបន្តផ្តល់ការធានារ៉ាប់រងដល់អ្នកត្រូវបានធានារ៉ាប់រងនូវអត្ថប្រយោជន៍ដែលនៅសល់ ២,៨៥០ដុល្លារអាមេរិក (=៥,០០០-២,១៥០)។

បណ្ណសន្យារ៉ាប់រងឆ្នាំទី១ ត្រូវបានបញ្ចប់

ឆ្នាំទី១

**បុព្វលាភធានារ៉ាប់រង ១៩៨.០៥ ដុល្លារអាមេរិក**

ឆ្នាំទី២

**បុព្វលាភធានារ៉ាប់រង ១៩៨.០៥ ដុល្លារអាមេរិក**

អត្ថប្រយោជន៍នៃ **PRUសុខភាពខ្ញុំ** មានសុពលភាពបន្តជាមួយការធានាពេញលេញនៅក្រោមបណ្ណសន្យារ៉ាប់រងនេះ

# PRU MyHealth

**ការបង្ហាញទី២៖** លោក ជា សំបូរ អាយុ៣០ឆ្នាំ ទិញ **PRUសុខភាពខ្ញុំ**កញ្ចប់សំរឹទ្ធ ដែលមានអត្ថប្រយោជន៍ចំនួន ៥,០០០ដុល្លារអាមេរិក។ គាត់ត្រូវបានវិនិច្ឆ័យថាមានជំងឺមហារីក។ គាត់បានទទួលការសម្រាកព្យាបាលទៅលើស្ថានភាពដែលមានការធានាជាមួយថ្លៃចំណាយជាក់ស្តែងសរុប២,០០០ដុល្លារអាមេរិក សម្រាប់ការទាមទារសំណងលើកដំបូង។បន្ទាប់មកមានការទាមទារសំណងលើកទី២ក្នុងកំឡុងឆ្នាំបណ្ណសន្យារ៉ាប់រងតែមួយ ដែលមានថ្លៃជាក់ស្តែងសរុប ៣,១០០ដុល្លារអាមេរិក ហើយវាត្រូវបានបញ្ជាក់ថាជាការព្យាបាលតែមួយដូចទៅនឹងការទាមទារសំណងលើកដំបូង។

| អត្ថប្រយោជន៍ | ថ្លៃចំណាយជាក់ស្តែង | អត្ថប្រយោជន៍ទូទាត់សំណងមុនពេលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកក្នុងការចំណាយ (២០%) | ក្រោយដកចេញការចូលរួមចំណែកក្នុងការចំណាយ (២០%) |
|---|---|---|---|---|
| ការព្យាបាលជំងឺមហារីក | $2,000 | $2,000 | $400 | $1,600 |
| ការកែតម្រូវលើដែនកំណត់នៃការចូលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកអតិបរមាក្នុងហេតុការណ៍តែមួយគឺ ១០០ ដុល្លារអាមេរិក។ទឹកប្រាក់ ៣០០ដុល្លារអាមេរិក ត្រូវបានសងត្រលប់ទៅអតិថិជនវិញ។ | | | $300 |
| **អត្ថប្រយោជន៍ត្រូវទូទាត់ជូន** | $2,000 | | $100 | **$1,900** |

| អត្ថប្រយោជន៍ | ថ្លៃចំណាយជាក់ស្តែង | អត្ថប្រយោជន៍ទូទាត់សំណងមុនពេលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកក្នុងការចំណាយ (២០%) | ក្រោយដកចេញការចូលរួមចំណែកក្នុងការចំណាយ (២០%) |
|---|---|---|---|---|
| ការព្យាបាលជំងឺមហារីក | $3,100 | $3,100 | $620 | $2,480 |
| ការកែតម្រូវលើដែនកំណត់នៃការចូលរួមចំណែកក្នុងការចំណាយ | ការចូលរួមចំណែកអតិបរមាក្នុងហេតុការណ៍តែមួយគឺបានទូទាត់នៅសំណងលើកទី១។ ដោយជាហេតុការណ៍តែមួយ ដូច្នេះមិនមានការចូលរួមចំណែកចំណាយទៀតទេ។ ទឹកប្រាក់៦២០ដុល្លារអាមេរិក ត្រូវបានសងត្រលប់ទៅអតិថិជនវិញ។ | | | $620 |
| **អត្ថប្រយោជន៍ត្រូវទូទាត់ជូន** | $3,100 | | $0 | **$3,100** |

**អ្នកត្រូវបានធានារ៉ាប់រងធ្វើរោគវិនិច្ឆ័យ និងទទួលការព្យាបាល**
អត្ថប្រយោជន៍ទូទាត់ជូនគឺ **១,៩០០ដុល្លារអាមេរិក** សម្រាប់សំណងលើកទី១។

**ជំងឺរបស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើងវិញ**
-បណ្ណសន្យារ៉ាប់រងបានផ្តល់ការធានារ៉ាប់រងដល់អ្នកត្រូវបានធានារ៉ាប់រងនូវអត្ថប្រយោជន៍ដែលនៅសល់**៣,១០០ដុល្លារអាមេរិក**។ អត្ថប្រយោជន៍សរុប**៥,០០០ដុល្លារអាមេរិក**ត្រូវបានទូទាត់ជូន **PRUសុខភាពខ្ញុំ** អស់សុពលភាព។
បណ្ណសន្យារ៉ាប់រងនៅតែបន្តធានារ៉ាប់រងលើករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍។

**ជំងឺរបស់អ្នកត្រូវបានធានារ៉ាប់រងកាន់តែធ្ងន់ធ្ងរហើយគាត់ទទួលមរណភាព**
-អត្ថប្រយោជន៍ធានារ៉ាប់រងលើករណីមរណភាព**៥,០០០ដុល្លារអាមេរិក**ត្រូវបានទូទាត់ជូន។អត្ថប្រយោជន៍សរុបទទួលបានគឺ**១០,០០០ដុល្លារអាមេរិក**។
បណ្ណសន្យារ៉ាប់រងអស់សុពលភាព។

ឆ្នាំទី១
**បុព្វលាភធានារ៉ាប់រង ១៧៤.៩៦ ដុល្លារអាមេរិក**

(*) ម្ចាស់បណ្ណសន្យារ៉ាប់រង និងក្រុមហ៊ុនរក្សាសិទ្ធិក្នុងការមិនបន្តបណ្ណសន្យារ៉ាប់រងឡើងវិញ។
(**) បុព្វលាភធានារ៉ាប់រងអាចប្រែប្រួលទៅតាមអតិផរណាផ្នែកវេជ្ជសាស្ត្រ ដែលការប្រែប្រួលនេះស្របតាមការអនុម័តពីនិយ័តករធានារ៉ាប់រងកម្ពុជា។

# ការពន្យល់និយមន័យនៅក្នុងបណ្ណសន្យារ៉ាប់រង

**ឆ្នាំបណ្ណសន្យារ៉ាប់រង** គឺជារយៈពេលចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រងរហូតដល់កាលបរិច្ឆេទខួបប្រចាំឆ្នាំនៃបណ្ណសន្យារ៉ាប់រងបន្ទាប់។

**ការសម្រាកព្យាបាល** សំដៅដល់រយៈពេលមួយដែលអ្នកត្រូវបានធានារ៉ាប់រងស្នាក់នៅក្នុងមន្ទីរពេទ្យរយៈពេល អប្បបរមា 6 ម៉ោងតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត និង បន្តស្នាក់នៅមន្ទីរពេទ្យរហូតដល់ពេលចាកចេញពីមន្ទីរពេទ្យ។  រយៈពេល អប្បបរមា 6 ម៉ោងក៏ត្រូវបានអនុវត្តក្នុងស្ថានភាពនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាពមុនរយៈពេល 6 ម៉ោង បន្ទាប់ពីចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ។ ការសម្រាកព្យាបាលនឹងត្រូវបញ្ជាក់តាមរយៈវិក្កយបត្របន្ទប់ និង ការស្នាក់នៅដែលចេញដោយ មន្ទីរពេទ្យ ហើយគ្មានកាលៈទេសៈណាដែលក្រុមហ៊ុននឹងបង់ថ្លៃចំណាយច្រើនជាងមួយ(1)ថ្ងៃនៃអត្ថប្រយោជន៍ប្រចាំថ្ងៃសម្រាប់ការស្នាក់នៅមន្ទីរពេទ្យក្នុងមួយ(1)ថ្ងៃឡើយ។.

**ការព្យាបាលដោយមិនចាំបាច់សម្រាកនៅមន្ទីរពេទ្យ** សំដៅដល់ការព្យាបាលដោយវេជ្ជសាស្ត្រអ្នកត្រូវបានធានារ៉ាប់រងទទួលបានពីស្ថាប័នផ្តល់សេវាព្យាបាលជំងឺដោយមិនចាំបាច់សម្រាកព្យាបាល ឬ មន្ទីរពេទ្យដែល បានបញ្ជាក់ដោយវេជ្ជបណ្ឌិត។

**រយៈពេលរង់ចាំ** សំដៅទៅលើរយៈពេលជាក់លាក់ណាមួយបន្ទាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រងឬបន្ទាប់ពីកាលបរិច្ឆេទបន្តសុពលភាពសន្យារ៉ាប់រងឡើងវិញ ឬកាលបរិច្ឆេទផ្លាស់ប្តូរផែនការសុខភាព (បន្ថែមអត្ថប្រយោជន៍ថ្មី ឬតម្លើង អត្ថប្រយោជន៍ដែលមានស្រាប់)នៃបណ្ណសន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែមនេះឬផលិតផលធានារ៉ាប់រងបន្ថែមណាមួយផ្សេងទៀតដោយយកកាលបរិច្ឆេទចុងក្រោយគេហើយនៅក្នុងអំឡុងពេលនេះនឹងមិនមានសំណងឬអត្ថប្រយោជន៍ណាមួយត្រូវផ្តល់ជូនទេ។

**កាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង** គឺជាកាលបរិច្ឆេទដែលត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ហើយគឺជាកាលបរិច្ឆេទដែលម្ចាស់បណ្ណសន្យារ៉ាប់រងបានបំពេញយ៉ាងត្រឹមត្រូវនូវទម្រង់បែបបទ ពាក្យស្នើសុំធានារ៉ាប់រង និងបង់បុព្វលាភធានារ៉ាប់រងគ្រប់ចំនួន ដោយយកកាលបរិច្ឆេទចុងក្រោយគេ យោងតាម ឯកសារនៃបណ្ណសន្យារ៉ាប់រងដូចមានចែងក្នុងឯកសារនេះ ដរាបណាអ្នកត្រូវបានធានារ៉ាប់រងនៅតែមានជីវិតនៅ កាលបរិច្ឆេទចេញវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។

**កាលបរិច្ឆេទបន្តសុពលភាពបណ្ណសន្យារ៉ាប់រង** គឺជាថ្ងៃនៃកាលបរិច្ឆេទខួបប្រចាំឆ្នាំនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ។



# ករណីមិនធានា

ករណីមិនធានាក្នុងការព្យាបាលវេជ្ជសាស្រ្តរួមមានប៉ុន្តែមិនកំណត់ចំពោះ៖

1. ស្ថានភាព ឬ ជំងឺមានពីមុនស្រាប់
2. ការព្យាបាលទៅលើភាពមិនប្រក្រតីពីកំណើត
3. ការមានគភ៌ ឬ ផលវិបាកនៃការមានគភ៌ ក្រៅពីស្ថានភាពជាក់លាក់ដែលត្រូវបានធានារ៉ាប់រង
4. ការព្យាបាលទៅលើអសមត្ថភាពផ្លូវភេទ ឬ ការគ្មានកូន
5. ការព្យាបាលបែបឯកជន ជំងឺអេដស៍ ឬ មេរោគ HIV ជំងឺទាក់ទងនឹងជំងឺអេដស៍ និងជំងឺឆ្លងណាមួយដែលតម្រូវដោយច្បាប់ឲ្យនៅដាច់ពីគេ
6. ជំងឺវិកលចរិក ជំងឺផ្លូវចិត្ត ឬ ជំងឺខ្លាច
7. ការរងរបួសដែលមកពីការចូលរួមសកម្មភាពដែលប្រឈមនឹងគ្រោះថ្នាក់
8. ការប៉ុនប៉ងធ្វើអត្តឃាត ការធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង
9. ការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ
10. ការព្យាបាលពីអ្នកអនុវត្តវេជ្ជសាស្រ្តដែលជាសាច់ញាតិ
11. សង្គ្រាម ការរំលោភបំពាន ការបំលែងកាំរស្មី ភេរវកម្ម
12. ការព្យាបាលដែលមិនមានភាពចាំបាច់ផ្នែកវេជ្ជសាស្រ្ត (រួមបញ្ចូលការពិនិត្យកាយសម្បទាជាប្រចាំការព្យាបាលទាក់ទងនឹងការគ្មានកូន ការវះកាត់កែសម្ផស្ស ការព្យាបាលមាត់ធ្មេញ ការចាក់ប្រព័ន្ធភាពស៊ាំ ជាដើម)
13. ការធ្វើដំណើរតាមផ្លូវអាកាសជាលក្ខណ:ឯកជនដែលមិនមែនជាអ្នកដំណើរដែលត្រូវបង់ប្រាក់ថ្លៃធ្វើដំណើរ

*កំណត់ចំណាំ៖*

- *សូមអានឯកសារបណ្ណសន្យារ៉ាប់រងសម្រាប់ព័ត៌មានលម្អិតចំពោះករណីមិនធានា និងរយ:ពេលរង់ចាំ*
- *ផលិតផលធានារ៉ាប់រងបន្ថែម PRU សុខភាពខ្ញុំត្រូវតែទិញជាមួយផលិតផល PRU អ្នកការពារ*

## ចំណុចសំខាន់ផ្សេងទៀតរបស់ **PRUសុខភាពខ្ញុំ**

- អាយុត្រូវបានធានារ៉ាប់រង ១០ - ៦០ ឆ្នាំ
- អាយុផុតកំណត់ធានារ៉ាប់រង ៧០ ឆ្នាំ
- រយៈពេលកំណត់ ១ឆ្នាំ និងបន្តសុពលភាពរៀងរាល់ឆ្នាំ

---

- អ្នកត្រូវបានធានារ៉ាប់រងទី១អាចជាវកញ្ចប់ណាមួយក្នុងកញ្ចប់ **PRUសុខភាពខ្ញុំ**
- អ្នកត្រូវបានធានារ៉ាប់រងទី២ អាចជាវបានផលិតផលធានារ៉ាប់រងបន្ថែម **PRUសុខភាពខ្ញុំ** ដែលមានទំហំអត្ថប្រយោជន៍ស្មើ ឬទាបជាងអ្នកត្រូវបានធានារ៉ាប់រងទី១តែប៉ុណ្ណោះ





យើងខ្ញុំរីករាយនឹងជួយស្វែងរកជម្រើសដំណោះស្រាយដែលស័ក្តិសមបំផុតសម្រាប់អ្នក និងគ្រួសារអ្នក។

PRUDENTIAL

ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

## ទំនាក់ទំនងមកកាន់យើងខ្ញុំឥឡូវនេះ


023 964 222

1800 21 22 23 (ឥតគិតថ្លៃ)

info@prudential.com.kh

www.prudential.com.kh

អគារវីត្រាស់ថាវើរ៍ ជាន់ផ្ទាល់ដី, #២៤ ផ្លូវលេខ ១៦៩ (មហាវិថីឆេកូស្លូវ៉ាគី) សង្កាត់វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រលេខ ៤១៧


ក្រុមការងាររបស់យើងត្រៀមខ្លួនរួចរាល់សម្រាប់ឆ្លើយតបទៅនឹងរាល់សំណួរដែលអ្នកមាន